00753914

E138/1/1

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ដាក់ជូន ៖ អង្គជំនុំជម្រះសាលាដំបូង
ភាគីដាក់ឯកសារ ៖ សហព្រះរាជអាជ្ញា
ភាសាដើម ៖ អង់គ្លេស
កាលបរិច្ឆេទដាក់ឯកសារ ៖ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Nov-2011, 09:30
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារដែលបានស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public
ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:
ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:
ឈ្មោះមន្ត្រីដែលបានពិនិត្យ:
ហត្ថលេខា:

---

# បណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូង ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ

---

| ដាក់ដោយ៖ | ដាក់ជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម និល ណុន, ប្រធាន | អៀង ធីរិទ្ធ |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | **សហមេធាវីការពារក្ដី៖** |
| | ចៅក្រម យ៉ា សុខន | ផាត់ ពៅស៊ាង |
| | ចៅក្រម Jean-Marc LAVERGNE | Diana ELLIS |
| | ចៅក្រម យូរ ឧត្ដរា | **សហមេធាវីនាំមុខដើមបណ្ដឹង៖** ពេជ អង្គ Elisabeth SIMONNEAU FORT |

# I. សេចក្តីផ្តើម

1. អនុលោមតាមវិធាន ៨២(៦), ១០៤, ១០៥, ១០៦(២) និង១០៧ នៃវិធានផ្ទៃក្នុង[1] សហព្រះរាជអាជ្ញា ដាក់បណ្តឹងសាទុក្ខភ្លាមៗ ("បណ្តឹងសាទុក្ខ") ជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ("សេចក្តីសម្រេចដែលរងការជំទាស់")[2]។

2. ដោយផ្អែកលើសំអាងហេតុខាងក្រោម សហព្រះរាជអាជ្ញាយល់ឃើញថា (១) បណ្តឹងសាទុក្ខអាចទទួលយកបាន (២) សេចក្តីសម្រេចដែលរងការជំទាស់ឆ្លើយតបទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញ ដោយសារសេចក្តីសម្រេចនេះមានកំហុសអង្គច្បាប់ កំហុសអង្គហេតុ និងកំហុសជាក់ស្តែងមួយចំនួនទៀត ពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង (៣) ត្រូវទុកជាមោឃៈទៅលើសេចក្តីសម្រេចដែលរងការជំទាស់ ដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ (៤) សេចក្តីសម្រេចដែលរងការជំទាស់ ត្រូវតែកែប្រែ ដោយតម្រូវឲ្យជនជាប់ចោទបន្តស្ថិតក្នុងមន្ទីរឃុំឃាំង និងទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងវិធីកែលម្អសុខភាពផ្សេងទៀត ដោយត្រូវត្រួតពិនិត្យមើល ក្នុងរយៈពេល ០៦ ខែ ខាងមុខ និង (៥) ផ្តល់ការអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាដើម្បីឲ្យខ្លួនអាចដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែម ដើម្បីគាំទ្រដល់បណ្តឹងសាទុក្ខនេះ។

# II. ឧត្ថិករណ៍

## ក. បណ្តឹងសាទុក្ខអាចទទួលយកបាន

3. បណ្តឹងសាទុក្ខឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវសម្រាប់ការទទួលយក ដូចដែលបានចែងក្នុងមាត្រា ១០៤, ១០៥ និង១០៧ នៃវិធានផ្ទៃក្នុង ជាពិសេស៖

   (ក) វិធាន ១០៤(៤)(ក) ចែងអំពីសិទ្ធិប្តឹងសារទុក្ខភ្លាមៗ ជំទាស់ទៅនឹងសេចក្តីសម្រេចដែលមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធី។ ដូចដែលសំអាងហេតុខាងក្រោមបញ្ជាក់សេចក្តីសម្រេចដែលរងការជំទាស់នឹងបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទ អៀង ធីរិទ្ធ ភ្លាម ("ជនជាប់ចោទ")។

[1] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៨) ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១ ("វិធានផ្ទៃក្នុង")

[2] ឯកសារលេខ **E138** សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១

(ខ) វិធាន ១០៤(៤)(ខ) ចែងអំពីសិទ្ធិប្តឹងសាទុក្ខភ្លាមៗ ជំទាស់ទៅនឹងសេចក្តីសម្រេចអំពីការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតុលាការ អនុលោមតាមវិធាន៨២។ សេចក្តីសម្រេចដែលរងការជំទាស់ បង្គាប់ឲ្យដោះលែងជនជាប់ចោទ ពីមន្ទីរឃុំឃាំងនៃ អ.វ.ត.ក ហេតុដូច្នេះ នេះគឺជាសេចក្តីសម្រេច ដែលធ្វើឡើង ដោយអនុលោមតាមវិធាន ៨២។

(គ) វិធាន១០៥(២) តម្រូវថា បណ្តឹងសាទុក្ខភ្លាមៗ ត្រូវបញ្ជាក់មូលដ្ឋានគាំទ្របណ្តឹងសាទុក្ខ និងទឡ្ហីករណ៍នានា។ វិធាននេះចែងថា មូលដ្ឋាននីមួយៗនៃបណ្តឹងសាទុក្ខត្រូវ ក) បញ្ជាក់អំពីកំហុសអង្គច្បាប់ និងត្រូវបង្ហាញថាកំហុសនោះបណ្តាលឲ្យសេចក្តីសម្រេចមានមោឃភាព ខ) បញ្ជាក់អំពីកំហុសដែលស្តែងឡើងពីការប្រើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនាំឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ម្ចាស់បណ្តឹងសាទុក្ខ ឬ គ) ត្រូវបញ្ជាក់ពីកំហុសអង្គហេតុ និងបង្ហាញកំហុសអង្គហេតុ ដែលនាំឲ្យសេចក្តីសម្រេចនោះមិនមានភាពយុត្តិធម៌។ មូលដ្ឋាននៃបណ្តឹងសាទុក្ខ ដែលមាននៅខាងក្រោមបង្ហាញកំហុសអង្គច្បាប់ ដែលនាំឲ្យមោឃៈ សេចក្តីសម្រេចដែលរងការជំទាស់, បង្ហាញកំហុសនៃការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបណ្តាលឲ្យមានការប៉ះពាល់ដល់សិទ្ធិរបស់សហព្រះរាជអាជ្ញា និងបង្ហាញ កំហុសអង្គហេតុដែលនាំឲ្យមិនមានភាពយុត្តិធម៌។

(ឃ) ជាទីបញ្ចប់ បណ្តឹងសាទុក្ខនេះត្រូវបានដាក់ជូនទៅក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង ក្នុងរយៈពេល២៤ម៉ោង បន្ទាប់ពីមានការជូនដំណឹងស្តីអំពីសេចក្តីសម្រេចដែលរងការជំទាស់ ដោយអនុលោមតាមវិធាន ១០៦(២) និង១០៧(៣) នៃវិធានផ្ទៃក្នុង។

### ខ. បណ្តឹងសាទុក្ខស្របទៅនឹងបទដ្ឋាននៃការពិនិត្យឡើងវិញនៃបណ្តឹងសាទុក្ខ

### (i) សេចក្តីសម្រេចបង្គាប់ឲ្យដោះលែងគឺមានន័យស្មើនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយជាសេចក្តីសម្រេចដែលផ្អែកលើកំហុសអង្គច្បាប់

4. សេចក្តីសម្រេចដែលរងការជំទាស់នេះ បានបង្គាប់ឲ្យបំបែកបទចោទប្រឆាំងនឹងជនជាប់ចោទ ចេញពីដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០២ និងផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់

ចោទ និងបង្គាប់ឲ្យដោះលែងជនជាប់ចោទ ក្រោមលក្ខខណ្ឌមួយ នោះគឺជនជាប់ចោទត្រូវជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូង មុននឹងប្តូរអាសយដ្ឋានទៅកន្លែងផ្សេង។

5. បញ្ញត្តិតែមួយគត់សម្រាប់ការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញប្រឆាំងនឹងជនជាប់ចោទ គឺអ្វីដែលគេសន្មតថាជាសិទ្ធិរបស់សហព្រះរាជអាជ្ញា ក្នុងការស្នើសុំធ្វើការវាយតម្លៃស្ថានភាពជនជាប់ចោទឡើងវិញ និងការផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ ប្រឆាំងនឹងជនជាប់ចោទ ក្នុងករណីស្ថានភាពជំងឺរបស់ជនជាប់ចោទមានសភាពធូរស្រាលច្រើន។ ដើម្បីអនុវត្តសិទ្ធិនេះ អង្គជំនុំជម្រះសាលាដំបូងបានណែនាំឲ្យសហព្រះរាជអាជ្ញាបង្កើត “យន្តការត្រួតពិនិត្យស្ថានភាពសុខភាពរបស់ជនជាប់ចោទជាប់ជាប្រចាំ”។ ការណែនាំនេះពុំមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, កិច្ចព្រមព្រៀងឬវិធាន ឬក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ។ សហព្រះរាជអាជ្ញាគ្មានសិទ្ធិអំណាចបង្កើតយន្តការ ត្រួតពិនិត្យជនជាប់ចោទ ដែលបានដោះលែងនោះឡើយ។ ជាងនេះទៀត ដោយហេតុថា ជនជាប់ចោទត្រូវបានដោះលែង “ដោយឥតលក្ខខណ្ឌ” ទើបពុំមានហេតុផលណាមួយតម្រូវឲ្យជនជាប់ចោទត្រូវព្យាបាល ឬធ្វើរោគវិនិច្ឆ័យបន្ថែមណាមួយ ទោះបីជាមានការស្នើសុំពីសំណាក់សហព្រះរាជអាជ្ញាក្តី។ ហេតុដូច្នេះ សហព្រះរាជអាជ្ញានឹងពុំអាចស្នើសុំផ្តួចផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញបានឡើយ ដោយ ហេតុថា សហព្រះរាជអាជ្ញា នឹងពុំមានលទ្ធភាពបង្ហាញថា ស្ថានភាពជំងឺរបស់ជនជាប់ចោទបានធូរ ស្បើយគួរឲ្យកត់សម្គាល់ឡើយ។

6. ជាងនេះទៅទៀត សេចក្តីសម្រេចនេះគឺពិតជាមានតម្លៃស្មើទៅនឹងការបញ្ចប់កិច្ចដំណើរការនីតិវិធី។ ដោយសហព្រះរាជអាជ្ញាពិចារណាឃើញថា ចៅក្រមជាតិទាំងបីរូប សុទ្ធតែបានយល់ថា “ស្ថានភាពជំងឺរបស់ជនជាប់ចោទ អៀង ធីរិទ្ធ អាចធូរស្បើយ” ដោយសារការព្យាបាល និងការមើលថែត្រឹមត្រូវ ទើបអង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានគតិយុត្តិណាមួយ ដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទនោះទេ។

### *(ii) ការលើកសំអាងហេតុថា ជនជាប់ចោទ ពុំអាចត្រូវបានឃុំខ្លួន ឬបង្ខាំង ហើយដីកាសម្រេចដោះលែង ធ្វើឡើងដោយមានកំហុសអង្គហេតុ និងអង្គច្បាប់ និងកំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិ*

7. ជាជម្រើសម្យ៉ាងទៀត អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ខ្លួនពុំមានឆន្ទានុសិទ្ធិ ដើម្បីបន្តឃុំខ្លួនជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក ឬទីកន្លែងណាផ្សេង ត្រូវបានធ្វើឡើងដោយមានកំហុសអង្គច្បាប់។ អង្គជំនុំជម្រះសាលាដំបូងបានគូសបញ្ជាក់ថា៖

> *ដូច្នេះ យោងទៅលើការរកឃើញរបស់ខ្លួនអំពីភាពគ្មានសមត្ថភាពក្នុងការចូលរួមការជំនុំជម្រះក្តី និងការបំបែកបទចោទទាំងអស់ប្រឆាំងនឹងជនជាប់ចោទរូបនេះ ...ដោយអនុលោមតាមវិធាន ៨៩ ស្ទួនពីរ និងការផ្អាកកិច្ចដំណើរការនីតិវិធីលើរូបគាត់ក្នុងសំណុំរឿង ០០២ នោះ អង្គជំនុំជម្រះសាលាដំបូងពុំមានមូលដ្ឋានណាមួយដើម្បីបន្តឃុំខ្លួនជនជាប់ចោទតទៅទៀតបានទេ*[3] ។

8. អង្គជំនុំជម្រះសាលាដំបូងពុំបានបង្ហាញមូលដ្ឋានគតិយុត្តិណាមួយ ចំពោះសំអាងហេតុដែលខ្លួនបានលើក រកឃើញឡើយ ពិសេសខ្លួនពុំបានយកវិធាន ៦៣ វិធាន ៦៤ និង វិធាន ៨២ ដែលចែងអំពីការឃុំខ្លួនបណ្តោះអាសន្ន មកធ្វើការពិនិត្យពិចារណាឡើយ។

9. វិធាន ៨២ (១) ចែងថា ក្នុងករណីដែលជនជាប់ចោទត្រូវបានឃុំខ្លួន នៅពេលចូលខ្លួនលើកដំបូងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ជនជាប់ចោទត្រូវស្ថិតនៅក្នុងឃុំដដែល រហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូង ត្រូវបានសម្រេចសេចក្តី។ វិធាន ៨២(២) ចែងថាអង្គជំនុំជម្រះសាលាដំបូង បង្គាប់ឲ្យដោះលែងជនជាប់ចោទ ឬដាក់ជនជាប់ចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ "ស្របតាមវិធានផ្ទៃក្នុងនេះ"។ សហព្រះរាជអាជ្ញាសូមអះអាងថា អង្គជំនុំជម្រះសាលាដំបូងគួរយកវិធាន ៦៣ និងវិធាន ៦៤ មកអនុវត្ត ដោយហេតុថា វិធានទាំងពីរនេះមានចែងអំពីលក្ខខណ្ឌសំខាន់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន។

10. វិធាន៦៤ ចែងអំពីការដោះលែងជនជាប់ចោទពីមន្ទីរឃុំឃាំងបណ្តោះអាសន្នល្គឹកណា "លក្ខខណ្ឌតម្រូវនៃការឃុំខ្លួនបណ្តោះអាសន្ន ដូចមានចែងក្នុងវិធាន ៦៣ ...លែងមានទៀតហើយ"។ ក្នុងចំណោមលក្ខខណ្ឌតម្រូវទាំងនេះរួមមាន "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម" និងការជឿថា ការឃុំខ្លួនបណ្តោះអាសន្នមានភាពចាំបាច់ដើម្បី៖ រារាំងកុំឲ្យជនជាប់ចោទគាបសង្កត់សាក្សី ឬជនរងគ្រោះ ថែរក្សា និងការពារមិនឲ្យជនជាប់ចោទបំផ្លាញភស្តុតាង ធានាបាននូវវត្តមានរបស់ជនជាប់ចោទ នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខរបស់ជនជាប់ចោទ ឬ រក្សាសណ្តាប់ធ្នាប់សាធារណៈ។

[3] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៦១។

11. ក្នុងករណីនេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេច*ផ្អាក*ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទរូបនេះ។ យ៉ាងហោចណាស់ ក៏ដំណើរការនីតិវិធីនៅកំពុងតែបន្តទៅមុខដែរ។ អាស្រ័យហេតុនេះ មូលដ្ឋានតែមួយគត់ ដែលអាចឲ្យដោះលែងពីការឃុំខ្លួនជាបណ្តោះអាសន្នបាន លុះត្រាតែលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នលែងត្រូវបំពេញតទៅទៀត ដូចមានចែងក្នុងវិធាន ៦៣ នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងនូវលក្ខខណ្ឌទាំងនេះ នៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់ផង និងមិនបានបង្ហាញថាលក្ខខណ្ឌទាំងនោះលែងត្រូវបំពេញទៀត។ អង្គជំនុំជម្រះសាលាដំបូងក៏មិនបានពិចារណាទៅលើការអនុវត្តឲ្យបានត្រឹមត្រូវនូវឆន្ទានុសិទ្ធិរបស់ខ្លួន ទាក់ទងទៅនឹងវិធាន៦៣ វិធាន ៦៤ និងវិធាន ៨២ នៃវិធានផ្ទៃក្នុង។

12. អង្គជំនុំជម្រះសាលាដំបូង ក៏ខកខានមិនបានអនុវត្តគោលការណ៍ជាសារវ័ន្តនៃច្បាប់ព្រហ្មទណ្ឌ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិឲ្យបានត្រឹមត្រូវផងដែរ នៅពេលឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា "ការបន្តឃុំខ្លួន ឬការឃុំឃាំងដោយបង្ខំនៅក្នុងស្ថានភាពដែលមិនច្បាស់លាស់ ថាតើអង្គជំនុំជម្រះនឹងត្រូវធ្វើសវនាការនៅពេលណានោះ គឺជាការរំលោភសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងសិទ្ធិក្នុងការទទួលបានសេរីភាព"[4]។

13. ផ្ទុយពីនេះ វិធាន និងយុត្តិសាស្ត្រអន្តរជាតិបង្ហាញថា ការបន្តការឃុំខ្លួន ឬដោះលែង ដែលត្រូវអនុវត្តដោយមានលក្ខខណ្ឌតឹងរ៉ឹង គឺជា *និយាម* ទៅហើយ នៅពេលដែលដំណើរការនីតិវិធីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌអន្តរជាតិត្រូវផ្អាក ដោយសារតែការគ្មានសម្បទាគ្រប់គ្រាន់ ហើយនៅតែមានលទ្ធភាព (សូម្បីតែលទ្ធភាពតិចក្តី) ថា ជនជាប់ចោទអាចមានសមត្ថភាពប្រសើរជាមុន។ តាមពិត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (ICTY) បានបង្គាប់ថា ត្រូវអនុវត្តលក្ខខណ្ឌផ្សេងទៀតចំពោះការឃុំខ្លួន និង/ឬ ការដោះលែង បើទោះជាក្នុងករណីជំងឺមិនអាចព្យាបាលជាក្តី។ ក្នុងសំណុំរឿង *Talić* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ស្ថានភាពរបស់ជនជាប់ចោទ "*មិនអាចព្យាបាលជា* និងមិនដំណើរការ ហើយ *មានតែអាចយ៉ាប់ទៅៗ* បើទោះជាមាន ឬគ្មានការព្យាបាលក្តី[5]។ យ៉ាងណាក៏ដោយ ស្ថានភាពរបស់ជនជាប់ចោទមិនបានបញ្ចប់ដំណើរការនីតិវិធី ដែលកំពុងបន្ត

---

4 សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៨០។

5 *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radolav Brđanin & Momir Talić*, សំណុំរឿងលេខ IT-99-36-T, សេចក្តីសម្រេចលើញត្តិសុំដោះលែងជនជាប់ចោទ Momir Talić ជាបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY) ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០២ ត្រង់លេខ៦ (គូសបញ្ជាក់បន្ថែម)។

ប្រឆាំងនឹងជនជាប់ចោទឡើយ រហូតដល់ជនជាប់ចោទនោះស្លាប់[6] ដោយអង្គជំនុំជម្រះបានបង្គាប់ឲ្យគាត់ "រស់នៅ និងនៅតែរស់នៅគ្រប់ពេលទាំងអស់ក្នុងអាសយដ្ឋាន (របស់គាត់) នៅ Belgrade លើកលែងតែនៅពេលខ្លះ ដែលជនជាប់ចោទតម្រូវឲ្យទៅពិនិត្យ និងព្យាបាលតាមបែបវេជ្ជសាស្ត្រ និងដោយចលនាប៉ុណ្ណោះ"[7]។ ដូចគ្នាដែរ នៅក្នុងសំណុំរឿង *Đukić* អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ជនជាប់ចោទ "កំពុងកើតជំងឺមួយដែលមិនអាចព្យាបាលជា ហើយតាមយោបល់អ្នកជំនាញផ្នែកវេជ្ជសាស្ត្រ ជំងឺនេះកំពុងស្ថិតក្នុងដំណាក់កាលជិតស្លាប់ហើយ"[8]។ អង្គជំនុំជម្រះសាលាដំបូងបានដាក់ "លក្ខខណ្ឌតឹងរ៉ឹង" ចំពោះជនជាប់ចោទ ដោយតម្រូវឲ្យគាត់ជូនដំណឹងទៅប្រធានរដ្ឋបាលតុលាការពីការផ្លាស់ប្តូរ អាសយដ្ឋានណាមួយ ឲ្យគាត់បញ្ជូនរបាយការណ៍វេជ្ជសាស្ត្រឲ្យបានទៀងទាត់ និងឆ្លើយតបទៅ នឹងដីកាកោះហៅផ្សេងៗ ប្រសិនបើស្ថានភាពជំងឺរបស់គាត់មានភាពប្រសើរឡើង[9]។

14. វិធានស្តីពីភស្តុតាង និងនីតិវិធីនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) គាំទ្រចំពោះវិធីសាស្ត្រនេះ ដោយតម្រូវឲ្យដំណើរការនីតិវិធីផ្អាក ប្រសិនបើជនជាប់ចោទត្រូវបានយល់ឃើញថាមិនមានសម្បទាគ្រប់គ្រាន់ ហើយត្រូវពិនិត្យទៅលើសម្បទាក្នុងរយៈពេល ១២០ ថ្ងៃ បើសិនជាគ្មាន "សំអាងហេតុក្នុងការមិនត្រូវពិនិត្យនេះទេ"[10]។ នៅក្នុងរយៈពេលផ្អាកដែលត្រូវបានកំណត់នេះ ពុំមានបទប្បញ្ញត្តិណាចែងសម្រាប់ការដោះលែងជនជាប់ចោទឡើយ។

---

[6] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Radolav Brđanin & Momir Talić*, សំណុំរឿងលេខ IT-99-36-T, ដីកាសម្រេចលប់ចោលកិច្ចដំណើរការនីតិវិធីប្រឆាំងនឹង Momir Talić (អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY) ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៣។

[7] *ដូចជើងទំព័រខាងលើ* ទំព័រ៩។

[8] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Đorđe Đukić*, សំណុំរឿងលេខ IT-96-20-T, សេចក្តីសម្រេចបដិសេធពាក្យសុំដកដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាសម្រេចដោះលែងបណ្តោះអាសន្ន (អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY) ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ត្រង់លេខ៣។

[9] *ដូចជើងទំព័រខាងលើ*, ត្រង់លេខ៥។

[10] វិធាននីតិវិធី និងភស្តុតាងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC), ឯកសារលេខ ICC-ASP/1/3 (ផ្នែកទី II-A), ត្រូវបានអនុម័តនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០២ ចូលជាធរមានថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០០២ មាត្រា ១៣៥(៤)។

15. សំអាងហេតុដែលថា អ.វ.ត.ក ពុំមានយុត្តាធិការក្នុងការឃុំខ្លួនជនជាប់ចោទ និងថា ការឃុំខ្លួនដូច្នេះនឹងរំលោភបំពានចំពោះសិទ្ធិរបស់គាត់ក្នុងការទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវ ប្រាកដជាសន្មតថា ស្ថានភាពជំងឺរបស់ជនជាប់ចោទមិនអាចនឹងមានភាពប្រសើរគ្រប់គ្រាន់ដើម្បីឲ្យគាត់មានលទ្ធភាពចូលរួមសវនាការឡើយ។ ដូច្នេះ សំអាងហេតុនេះផ្អែកទៅលើការភ័ន្តច្រឡំផ្នែកអង្គហេតុដោយមិនគិតគូរចំពោះយោបល់អ្នកជំនាញដែលថា វិធានការផ្នែកវេជ្ជសាស្ត្រ ឬការប្រើវិធីកែលម្អស្ថានភាពសុខភាពផ្សេងទៀត អាចធ្វើឲ្យស្ថានភាពជំងឺរបស់ជនជាប់ចោទមានភាពប្រសើរឡើង។ ជាឧទាហរណ៍ អ្នកជំនាញបានផ្តល់សក្ខីកម្មដូចខាងក្រោម៖

<u>ប្រតិចារឹកចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១១ ឯកសារ E1/9.1, ទំព័រ៩៣ [សាស្ត្រាចារ្យ Campbell]</u>

*ឆ. អ្វីដែលខ្ញុំលើកឡើងនៅពេលនេះនោះគឺថា នៅពេលដែលយើងប្រើប្រាស់ឲ្យគ្រប់លទ្ធភាពទាំងអស់ ហើយសាកល្បងគ្រប់វិធានការទាំងអស់ដើម្បីព្យាយាម និងកែលម្អមុខងារ យើងមិនអាចប្រាកដថា គាត់មិនអាចមានលទ្ធភាពចូលរួមក្នុងការចូលរួមការការពារក្តីនោះទេ។ ដូចខ្ញុំបាននិយាយរួចហើយ ខ្ញុំគិតថាវាប្រហែលជាមិនអាចទេ ប៉ុន្តែយើងគួរតែសាកល្បង ដើម្បីជាប្រយោជន៍ដល់គាត់។*

*ស. តើលោកគិតថាវាជាការសមស្របដែលលោកគួរធ្វើកោសល្យវិច័យឡើងវិញ ក្រោយពីការធ្វើការសាកល្បងការព្យាបាលដែលអ្នកបានណែនាំ?*

*ឆ. ប្រសិនបើជាបំណងរបស់តុលាការ នោះខ្ញុំនឹងអនុវត្តដូច្នេះ។*

*ស. ដោយសារខ្ញុំជិតបិទការសាកសួរនេះហើយ។ នៅក្នុងអនុសាសន៍របស់លោក និងការព្យាបាលបន្តទៀតនោះ យើងអាចនិយាយបានដែរឬទេថាសេចក្តីសន្និដ្ឋានរបស់លោកនេះ ជាសេចក្តីសន្និដ្ឋានបណ្តោះអាសន្ន?*

*ឆ. ខ្ញុំគិតថា ជាការសន្និដ្ឋានគឺថា វាអាចមានការប្រែប្រួល ហើយក៏មានការវាយតម្លៃដោយអ្នកជំនាញផ្សេង ទៀតដែរ។ ដូច្នេះជាសេចក្តីសន្និដ្ឋានរបស់ខ្ញុំ ខ្ញុំគិតថា ការសន្និដ្ឋានទាំងនោះមិនមែនជាការសន្និដ្ឋានចុងក្រោយ បន្ទាប់ពីយើងសាកល្បងប្រើវិធានការផ្សេងទៀតទាំងអស់។*

<u>ប្រតិចារឹកចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ឯកសារ E1/12.1, ទំព័រ៥៣ [Drs Fazel និង Lina]</u>

*ខ្ញុំគិតថា អ្នកក៏បានផ្តល់យោបល់ថា ស្ថានភាពរស់នៅរបស់គាត់នៅក្នុងមន្ទីរឃុំឃាំង មានន័យថាសកម្មភាព ដែលគាត់ធ្វើមានចំនួនតិចតួច និងក្រោមការកំហិត។ តើត្រូវទេ?*

*លោក. FAZEL:*

*ឆ. បាទ មែន។*

*ស. តើក្នុងស្ថានភាពបច្ចុប្បន្ននេះ វាអាចជារួមចំណែកចំពោះសុខមាលភាពផ្នែកចិត្តសាស្ត្ររួម និងមុខងារ សតិបញ្ញារបស់គាត់ដែរឬទេ?*

*លោក. FAZEL:*

*ឆ. បាទ។ វាពិតជាអាចរួមចំណែកណាស់ ដូចខ្ញុំបានលើកឡើងរួចហើយ បន្ទាត់ទី២០ ការជំរុញសតិបញ្ញាគឺជាផ្នែកយ៉ាងសំខាន់មួយក្នុងការព្យាយាមយ៉ាងហោចណាស់ បន្ទាត់ទី២១ កាត់បន្ថយល្បឿននៃការចុះថយនៃសតិបញ្ញា។*

<u>ប្រតិចារឹកចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១១ ឯកសារ E1/12.1, ទំព័រ៥៤ [Drs Fazel និង Lina]</u>

*លោកវេជ្ជបណ្ឌិត Fazel បានផ្តល់សក្ខីកម្មពីមុនមកថា លោកឯកភាពតាមលោកវេជ្ជបណ្ឌិត ខាំប៉ែល ចំពោះបញ្ហានៃការព្យាបាល។ ដូច្នេះ យើងអាចនិយាយបានថា លោកឯកភាពជាមួយគាត់ថា យើងគួរព្យាយាម ធ្វើការព្យាបាលនេះ?*

*លោក FAZEL:*

*ឆ. ខ្ញុំគិតថា យើងនិយាយថា ខ្ញុំមិនជំទាស់ជាមួយគាត់ទេដោយបញ្ហាថា ខ្ញុំគ្មានបទពិសោធន៍ព្យាបាល អ្នកជំងឺដែលប្រើថ្នាំ ដុនេណេប៉េហ្ស៊ីល (Donepezil)ទេ។ ដូច្នេះ ខ្ញុំមិនជំទាស់នឹងគាត់ទេ។*

16. អាស្រ័យលើភាពធ្ងន់ធ្ងរនៃបទចោទដែលជនជាប់ចោទប្រឈម វាគឺជាកំហុសជាក់ស្តែងផ្នែកឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ដែលខកខានមិនបានប្រើប្រាស់ឲ្យអស់ជម្រើសទាំងឡាយក្នុងការធ្វើឲ្យប្រសើរឡើងដល់ស្ថានភាពរបស់ជនជាប់ចោទ ដូចដែលអ្នកជំនាញបានផ្តល់អនុសាសន៍។

**(iii) សេចក្តីសម្រេចទៅលើថាតើត្រូវបន្តកិច្ចនីតិវិធីយ៉ាងដូចម្តេចនៅពេលគ្មានមតិភាគច្រើនលើសលប់ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ និង/ឬ កំហុសជាក់ស្តែងក្នុងការអនុវត្តឆន្ទានុសិទ្ធិ**

17. សេចក្តីសម្រេចដែលរងការជំទាស់កត់សម្គាល់ថា មាត្រា១៤(១)នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តម្រូវថា សេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះសាលាដំបូងតម្រូវឲ្យមានការបោះឆ្នោតគាំទ្រពីចៅក្រមបួនរូប (មតិភាគច្រើនលើសលុប) ប៉ុន្តែពុំមានសេចក្តីណែនាំនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក

កិច្ចព្រមព្រៀង ឬ វិធានផ្ទៃក្នុង ទាក់ទិននឹងផលវិបាកនៃការខ្វះមតិភាគច្រើនលើសលប់ឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសយក "បទដ្ឋានអន្តរជាតិជាសារវ័ន្ត" ដើម្បីជួយខ្លួនក្នុងការដោះស្រាយបញ្ហាដែលមានសារៈសំខាន់នេះ។ ក្នុងការធ្វើដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយកជំហរមួយដែលមានលក្ខណៈផ្ទុយស្រឡះ និងមិនសមហេតុផលទៀតផង ដែលតាមរយៈនេះជំហរមតិភាគតិចនៃចៅក្រមអន្តរជាតិ ទៅលើបញ្ហាដែលមានសារៈសំខាន់ បានគ្របដណ្តប់ទៅលើជំហរមតិភាគច្រើន។ ប្រការនេះមានន័យថាជាកំហុសអង្គច្បាប់ និង/ឬ ការប្រើឆន្ទានុសិទ្ធិខុស។

18. ការពិនិត្យមើលវិធានផ្ទៃក្នុងទាក់ទិននឹងបណ្តឹងឧទ្ធរណ៍ចំពោះមុខអង្គបុរេជំនុំជម្រះ និងបណ្តឹងសាទុក្ខនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ចង្អុលបង្ហាញថាក្នុងករណីមិនមានមតិភាគច្រើនលើសលប់ទេ នោះត្រូវយកតាមសេចក្តីសម្រេចពីមុន។ អាចនិយាយបានម្យ៉ាងទៀតថាជាដំណោះស្រាយគឺថាត្រូវរក្សា*ស្ថានភាពបច្ចុប្បន្ន* (*status quo*) ហើយនៅក្នុងករណីនេះគឺត្រូវរក្សាការឃុំខ្លួន។ ដើម្បីកាត់បន្ថយឱ្យដល់កម្រិតអប្បបរមានូវរយៈពេលនៃអសច្ចភាពផ្លូវច្បាប់ណាមួយសម្រាប់ជនជាប់ចោទដោយសារតែការខ្វះការព្រមព្រៀង អង្គជំនុំជម្រះសាលាដំបូងគួរតែបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការស្នើឱ្យភាគីដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរទាំងទៅលើបញ្ហាអង្គសេចក្តី និងនីតិវិធីដែលខ្លួនមិនយល់ស្រប។

## III. សំណើ

19. អាស្រ័យលើអង្គហេតុដែលបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាស្នើឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

**(ក)** ទុកជាមោឃៈនូវសេចក្តីសម្រេចដែលរងការជំទាស់ ត្រង់ចំណុចដែលសេចក្តីសម្រេចនេះបង្គាប់ឱ្យដោះលែងជនជាប់ចោទ ដោយគ្មានលក្ខខណ្ឌ។

**(ខ)** កែតម្រូវសេចក្តីសម្រេចដែលរងការជំទាស់ ដោយបង្គាប់ឱ្យជនជាប់ចោទបន្តស្ថិតនៅក្នុងការឃុំខ្លួន និងទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការថែលម្អសុខភាពផ្សេងទៀត ដូចដែលអ្នកជំនាញផ្នែកវេជ្ជសាស្ត្របានផ្តល់អនុសាសន៍ ដោយត្រូវធ្វើការត្រួតពិនិត្យសុខភាពឡើង វិញក្នុងរយៈពេល ០៦ ខែ។

20. សហព្រះរាជអាជ្ញាសូមស្នើបន្ថែមទៀត សុំអនុញ្ញាតដាក់សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរបន្ថែមគាំទ្រដល់បណ្តឹងសាទុក្ខនេះ ក្នុងរយៈពេលប្រាំពីរថ្ងៃ។ ដោយសារពេលវេលាខ្លីពេកក្នុងការប្តឹងសាទុក្ខដែលមានចែងក្នុងវិធានផ្ទៃក្នុង បណ្តឹងសាទុក្ខនេះមិនអាចបង្ហាញគ្រប់ឯកសារគាំទ្រ និងទឡ្ហីករណ៍ឡើយ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |